# ការរៀបចំព្រឹត្តិការណ៍សហគមន៍នៅពេលវត្តមានរបស់ ICE កើនឡើង

KHMER

ការជួបជុំគ្នាក្នុងសហគមន៍មានសារៈសំខាន់ ប៉ុន្តែយើងដឹងថាមនុស្សជាច្រើនបានបង្ហាញការព្រួយបារម្ភអំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ដែលអាចកើតមាននៅក្នុង ឬនៅជិតព្រឹត្តិការណ៍សហគមន៍។ មានជំហានមួយចំនួនដែលអ្នកអាចអនុវត្តដើម្បីជួយឱ្យសមាជិកសហគមន៍ទាំងអស់មានអារម្មណ៍ស្ងប់ចិត្តកាន់តែច្រើនពេលចូលរួមព្រឹត្តិការណ៍សហគមន៍។

## ពិចារណាអំពីទីកន្លែង

- ព្រឹត្តិការណ៍សហគមន៍ជាច្រើនត្រូវបានរៀបចំឡើងនៅទីសាធារណៈ។ ទោះជាយ៉ាងណា ប្រសិនបើព្រឹត្តិការណ៍របស់អ្នកជាព្រឹត្តិការណ៍ឯកជន ឬមានការកំណត់ការចូលរួម មន្ត្រី ICE នឹងអាចចូលបានតែក្នុងករណីមានការយល់ព្រមឱ្យចូល ឬមានដីកាដែលចេញដោយចៅក្រម។
- ពិចារណាថាតើការឱ្យអ្នកចូលរួមចុះឈ្មោះ ការចេញសំបុត្រ ឬការឱ្យអ្នកចូលរួមចុះវត្តមាននៅច្រកចូល អាចសមស្របសម្រាប់ព្រឹត្តិការណ៍របស់អ្នកដែរឬទេ។

## បណ្តុះបណ្តាលអ្នករៀបចំព្រឹត្តិការណ៍

- កំណត់បុគ្គលទំនាក់ទំនងកណ្តាលម្នាក់ (ល្អបំផុតគឺមេធាវី និង/ឬពលរដ្ឋសហរដ្ឋអាមេរិក) ដើម្បីទាក់ទងជាមួយមន្ត្រី ICE ប្រសិនបើចាំបាច់ ហើយធានាថាអ្នករៀបចំព្រឹត្តិការណ៍ទាំងអស់មានការតភ្ជាប់គ្នា (ឧ. បង្កើតក្រុមជជែក WhatsApp ឬ Signal សម្រាប់អ្នករៀបចំព្រឹត្តិការណ៍)។
- ពិចារណាបង្កើតក្រុមអ្នកសម្របសម្រួលសណ្តាប់ធ្នាប់ព្រឹត្តិការណ៍ និងផ្តល់ការបណ្តុះបណ្តាលអំពីការបន្ធូរស្ថានការណ៍តានតឹងដល់ពួកគេ។
- ធ្វើឱ្យវត្តមានរបស់អ្នករៀបចំមើលឃើញច្បាស់ ដើម្បីបង្កើតអារម្មណ៍ថាមានការទទួលខុសត្រូវ (ឧ. ពិចារណាឱ្យអ្នករៀបចំព្រឹត្តិការណ៍មួយចំនួនពាក់អាវកាក់ពណ៌ភ្លឺ ដើម្បីងាយស្រួលមើលឃើញ)។

## គាំទ្រអ្នកចូលរួម

- សូមធានាថា អ្នកចូលរួមគ្រប់រូបមានប័ណ្ណ Know Your Rights («ស្គាល់សិទ្ធិរបស់អ្នក»)។
- រៀបចំតុធនធាន KYR និងផ្តល់ឱកាសឱ្យអ្នកចូលរួមសួរសំណួរ (សូមមើលលេខកូដ QR សម្រាប់សម្ភារៈដែលអាចបោះពុម្ពបានជាច្រើនភាសា)។ ពិចារណាប្រមូលព័ត៌មានទំនាក់ទំនងបន្ទាន់សម្រាប់អ្នកដែលចូលរួម ដើម្បីឱ្យអ្នកដឹងថាត្រូវទាក់ទងនរណា ប្រសិនបើមានអ្វីមួយកើតឡើង។
- ជូនដំណឹងដល់អ្នកចូលរួមអំពីទីកន្លែងដែលបានកំណត់ ដែលពួកគេអាចប្រមូលផ្តុំគ្នាបានក្នុងករណីមានស្ថានការណ៍បន្ទាន់។
- គិតពិចារណាអំពីរបៀបដែលអ្នកចូលរួមនឹងធ្វើដំណើរមកព្រឹត្តិការណ៍ និងត្រឡប់ទៅផ្ទះវិញ ហើយថាតើមានការគាំទ្រណាមួយដែលអ្នកអាចរៀបចំបានដែរឬទេ។
- ធនធាន KYR ដែលអាចបោះពុម្ពបាន

ធនធាន KYR
ដែលអាច
បោះពុម្ពបាន

ខែមិថុនា ឆ្នាំ 2025

MIRA